BMI0037

# សម្ភាសន៍ជាមួយឈ្មោះ សូ រី ភេទស្រី អាយុ៥៧ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានផ្នែកក្រឡឹងដែក នៅឫស្សីកែវ

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិត្រពាំងកក់ ឃុំស្វាយរំពា ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុផានី

០០:៤៩:០៧

២៥ទំព័រ

ផានី ៖ ថ្ងៃទី១៦ ខែតុលា ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកនេះចង់សាកសួរពីប្រវត្តិរបស់មីងដែលមីធ្លាប់ឆ្លងកាត់មកដល់ម៉ាឡៃនឹងជួបរឿងអីខ្លះ ឃើញទិដ្ឋភាពមកដល់ទីនេះ ។ ហើយខ្ញុំសុំយកប្រវត្តិអស់នឹងមកធ្វើជាសៀវភៅ ក៏ទុកជាឯកសារសម្រាប់ក្មេងៗ ឬអ្នកស្រាវជ្រាវផ្សេង យកមកស្រាវជ្រាវសម្រាប់ក្មេងក្រោយៗបានអាន បានមើលដឹង ។ មីងអនុញ្ញាតិអត់?

រី ៖ បាន ។

ផានី ៖ ខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតជារូបបានអត់?

រី ៖ បាន ។

ផានី ៖ មីងមានឈ្មោះអីដែរ?

រី ៖ ខ្ញុំឈ្មោះ ត្រកូល សូ រី ។

ផានី ៖ មីងមានឈ្មោះក្រៅទេ?

រី ៖ មានដែល ប៉ុនចាស់នៅស្រុក ចាស់ហៅពាក្យស្រឡាញ់ពាក្យអី ហៅខ្ទួន ហៅមីនាងចាស់ៗ ប៉ុនមកយើងនេះប្រើតែពាក្យនឹងមួយទេ តែឈ្មោះមួយទេ ។

ផានី ៖ មីងមានស្រុកកំណើតនៅណាដែរ?

រី ៖ ខ្ញុំនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ផានី ៖ ភូមិឃុំអីដែរ?

រី ៖ នៅភូមិត្រពាំងកក់ ស្រុកយើងនោះ ឃុំស្វាយរំពា ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ធានី ៖ មីងឆ្នាំនឹងអាយុប៉ុន្មានហើយ?

រី ៖ ខ្ញុំសព្វថ្ងៃនេះ ៥៧ ។

ធានី ៖ មីងរាល់ថ្ងៃរស់នៅណាវិញ?

រី ៖ ខ្ញុំនៅភូមិនឹងដែរ ប៉ុនភូមិនៅជាប់ថ្នល់ នៅខាងផ្លូវធំ ។

ធានី ៖ ហៅភូមិអីគេ?

រី ៖ ភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកមីងឈ្មោះអីគេ?

រី ៖ ឪពុកខ្ញុំឈ្មោះ សូ ខុន ។

ធានី ៖ គាត់នៅរស់?

រី ៖ ស្លាប់តាំងពីយូរ ឆ្នាំ៧៨ ។

ធានី ៖ ដោយសារអីដែរ?

រី ៖ គាត់ដោយសារជម្ងឺគ្រុនចាញ់នៅស្រុកយើងពីដើម ។

ធានី ៖ ចុះម្តាយ?

រី ៖ ម្តាយគាត់នៅ ។

ធានី ៖ ឈ្មោះអីគេ?

រី ៖ ឈ្មោះ កយ សារ៉ាយ ។

ធានី ៖ គាត់ជាអី?

រី ៖ ឥឡូវគាត់ចាស់ហើយ គ្មានធ្វើអីកើតទេ ។

ធានី ៖ គាត់រស់នៅជាមួយមីងដែរ?

រី ៖ នៅស្រុកយើងនោះទេ ឪពុកម្តាយអត់មានមកនេះទេ មកតែខ្ញុំ និងក្មួយមួយនៅនេះ ។

ធានី ៖ ក្មួយមកជាមួយមីងឥឡូវ ឬមកយូរ?

រី ៖ មកៗឥឡូវបានប្រហែលជាកំឡុងខែនឹងឯង កាលពីមុនខ្ញុំនៅតែឯង ។

ធានី ៖ ចុះគ្រួសារមីង?

រី ៖ អត់មានផង ។

ធានី ៖ សុខចិត្តនៅលីវរហូតទាល់ឥឡូវ?

រី ៖ នៅលីវ ៗ នៅជាមួយប្អូនៗរាប់អានជិតគ្នាដូចផ្ទះជាប់គ្នា ឈឺយប់ព្រលប់ក៏គេមើល ប្អូនរាប់អានមួយគ្រាន់យើងថាជិតស្និត ។

ធានី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

វី ៖ ខ្ញុំមានបងប្អូន៦ ។

ធានី ៖ នៅរស់ទាំង៦?

វី ៖ ចាស!

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វី ៖ ស្រី៣ ប្រុស៣ ។

ធានី ៖ ហើយគាត់នៅជាមួយមីងដែរ?

វី ៖ អត់ទេ នៅតែខ្ញុំទេ និយាយទៅមកតែខ្ញុំជាប់មក៧៩ ។

ធានី ៖ ហើយម៉េចបានមកដល់នេះម្នាក់ឯង?

វី ៖ ជំនាន់យើងដូចថាជំនាន់យើងបែកភ្នំពេញហើយ យើងជំនាន់៧៩រត់មកក៏គេឲ្យថយមកជឹងគេមកដល់ចេញពីភ្នំពេញម៉ោង១១យប់ ។ ហើយដល់ពេលចេញមកដើរកាត់ភ្នំពេញក៏ជិះរទេះភ្លើងមកដល់បាត់ដំបង ។

ធានី ៖ ម៉េចទៀត?

វី ៖ មកដល់បាត់ដំបង ក៏ចាប់ដើរពីបាត់ដំបងដើររបូត(រហូត) ចេះនាំគ្នាដើរទាំងគេទាំងយើងទាំងអស់គ្នា អ្នកដែលរត់៧៩ ។ ហើយរត់មកធ្លាក់វែងឆ្ងាយ ដើរពីនឹងមកខ្សែម១ មកត្រាង បានយើងស្រុកម៉ាឡៃយើងនេះ តាំងពី៧៩ចូល៨០ចូលស្រុកម៉ាឡៃ ដើរកាត់វាលហោង ។ មុនមិនវាលចេះទេ ព្រៃហោងពីដើមដីខ្វាទៅ ហើយទើបបានជាប់កកើតដឹកជញ្ជូន ដែលយើងជំនាន់ខ្មែរវៀតនួនណោះណា ។ យើងនិយាយតាមដំណើររឿង ព្រោះខ្ញុំចូលមកដល់ដំបូងដឹកជញ្ជូន អត់មានរៀបជាអង្គភាពដឹកជញ្ជូន ។

ធានី ៖ ម៉េចទៀតមីង?

វី ៖ មានអីរៀបអង្គភាពដឹកជញ្ជូន ជាកងជាក្រុមតាមអង្គភាពផ្សេងៗគ្នា ដូចខ្ញុំក្រុមផ្សេង កងផ្សេងរៀបជាអង្គភាព តាមវរសេនាតូច វរសេនាធំ ។ ពីមុនព្រៃ ប៉ុនយើងចេះវាទទៅ យើងមានគ្រួសារម្នាក់កាប់បន្តិចៗ ក៏វាលណា អត់មានអីទេខ្ញុំ ចេញមកនៅដឹកជញ្ជូន អស់ពីដឹកជញ្ជូនក៏នៅជាមួយប្អូនគេមានគ្រួសារមានអីធ្វើអី ។ គេមេយើងកូន គេប្រើយើងដឹកជញ្ជូន អត់មានដូចថាជំនាន់នោះគេបើកអង្ករឲ្យហូប ដល់ពីផ្តាច់អង្ករមក យើងមានអីយើងកាប់ចំការ វាទដីស្រែចំការខ្លួនយើងគ្រាន់វាហាត់ទិញ ដីព្រៃស្រាប់ ។ ហើយមុខរបររាល់ថ្ងៃគ្មានលក់ដូរអីទេ ធ្វើស្រែធ្វើចំការទេ ។ មានអីទៀត មានតែប៉ុននឹង ខ្ញុំអត់និយាយអីវែងឆ្ងាយ ៧៩មកយើងដឹកជញ្ជូន ចប់ពីដឹកជញ្ជូនមកយើងរំសាយអង្គភាពដឹកជញ្ជូន យើងរស់តាមភូមិតាមក្រុម ពីមុនជា

រួម ៗ ពីមុនអង្គភាពកងទ័ព អង្គភាពយោធា យើងនៅចំរុះជាគ្រួសារយោធា ដល់កើតឡើងពីដី ថៃមកដីយើង ចែកជាភូមិជាក្រុមចែកនៅតាមរៀងៗខ្លួន មានអីទេពី៧៩មក ខ្ញុំគ្មានអីទេ ។

ធានី ៖ មីងកាលពេលមកដល់៧៩ មីងថារត់ពីណា រត់ពីភ្នំពេញមក?

រី ៖ រត់ពីភ្នំពេញមក ។

ធានី ៖ ម៉េចមីងរត់ពីភ្នំពេញ ស្រុកកំណើតមីងនៅកំពង់ស្ពឺ?

រី ៖ អត់ទេ យើងពីមុនអង្គភាព ។

ធានី ៖ អង្គភាពម៉េច?

រី ៖ អង្គភាពរោងចក្រ ជំនាន់នោះយើងនៅរោងចក្រ ។

ធានី ៖ រោងចក្រអីគេ?

រី ៖ កាលនឹងរោងចក្រក្រឡឹងដែក ។

ធានី ៖ ឆ្នាំប៉ុន្មាន?

រី ៖ កាលនឹងឆ្នាំ៧៧នោះ វាវែងឆ្ងាយយើងចេញពីផ្ទះមកជំនាន់តស៊ូ ជំនាន់យើងឆ្នាំ៧០ ៧១ ៧២ ៧៣ មកដល់៧៤យើងនៅតាមអង្គភាព នៅកងចល័តក៏មានច្រើនដំណើរបើនិយាយឲ្យ ប្រាកដ ៗ យើងនៅពីមុនកងទ័ពក្រសួងមន្ទីរ ចេញពីក្រសួងមន្ទីរមកដឹកដែលដឹកប្រឡាយដឹក ទំនប់ វាហួរហែលពិបាកកត់ ពិបាកវែងឆ្ងាយណាស់ តាំងពីជំនាន់នោះមកដល់ជំនាន់នេះយើង ម៉ាសម័យ៧៧ខ្ញុំនៅភ្នំពេញ ។ វែងឆ្ងាយណាស់ បើនិយាយទៅនេះ ពិបាកបើកត់ពីដើមភៀស ខ្លួននោះ ។

ធានី ៖ មីងនិយាយ៧០នឹងស្អីគេ?

រី ៖ ឆ្នាំ៧០យើងតស៊ូដំបូងកាលអាយុខ្ញុំ២០ ឥឡូវអាយុ៥៧ហើយវាច្រើនជំនាន់ ។

ធានី ៖ មីងចេញតាំងពីអាយុ២០មក?

រី ៖ ចា៎ស! ខ្ញុំចេញ ។

ធានី ៖ ធ្វើអីគេ ចេញពីផ្ទះនឹងមក?

រី ៖ ជំនាន់នឹង យើងទៅតាមសង្គម នៅយោធាក៏នៅ ដឹកជញ្ជូន សែនរបួសនិយាយសព្វបែបយ៉ាង ម៉ាដំណាក់កាលៗ ។

ធានី ៖ មីងអាចជួយប្រាប់បានទេ ឆ្នាំ៧០ធ្វើអី?

រី ៖ និយាយម៉ាដំណាក់ៗយើងនៅអង្គភាពក្រសួងមន្ទីរជំនាន់នោះ យើងវៃជាមួយអាមេរិចតាំងពីនឹង មកអ៊ីចូលយួរហើយ ។

ធានី ៖ មីងតាំង២-៣ជំនាន់?

រី ៖ ហ្នឹងហើយ តាំងពីអើយ២-៣ជំនាន់ ។

ធានី ៖ មីងអាចជួយប្រាប់តិចបានទេ តាំងពី៧០មកមីងធ្វើអី?

រី ៖ មានអី ។

ធានី ៖ ម៉េចខ្លះ ហើយបន្ទាប់មកទៀត ៧១មីងធ្វើអីគេ នៅជាមួយអ្នកណាគេ?

រី ៖ អឺ! ពិបាក វាវែងឆ្ងាយពេកចាំមិនអស់ទេ វាវែងឆ្ងាយណាស់ ចាំមិនអស់ទេច្រើនណាស់ ។

ធានី ៖ មីងនៅ៧០នៅធ្វើអីគេ នៅកន្លែងណា?

រី ៖ នៅក្រសួងមន្ទីរតាមឃុំ ។

ធានី ៖ នៅមន្ទីរអីគេ?

រី ៖ នៅមន្ទីរដូចយើងជំនាន់នៅក្រុមនារសានៅស្មើរ ។

ធានី ៖ ក្រុមនារសានៅមន្ទីរណា?

រី ៖ កាលនៅក្មេងក្មេចអស់ហើយ លែងវែងឆ្ងាយមិនបាច់កត់ច្រើនណាស់ យើងនៅអាយុ២០ជាង
រហូតដល់៥០ជាងវាចូល៣០ជាង ។

ធានី ៖ កាលនឹងមីងនៅក្រុមនារសានៅមន្ទីរ?

រី ៖ មន្ទីរឃុំស្វាយរំពា វែងឆ្ងាយណាស់មិនបាច់កត់ទេ ។

ធានី ៖ ហើយចេញពីនារសាឃុំទៅណា?

រី ៖ មកតំបន់ ។

ធានី ៖ តំបន់អីគេ?

រី ៖ តំបន់៣៣ គេហៅពីដើមតំបន់៣៣ខេត្តកំពង់ស្ពឺ ។

ធានី ៖ កាលនឹងនៅស្រុកអីតំបន់៣៣?

រី ៖ គេហៅស្រុក៩៣ សម័យឥឡូវគេហៅកំពង់ស្ពឺ ។

ធានី ៖ សម័យឥឡូវគេហៅស្រុកអីទៅ?

រី ៖ ឥឡូវវាចូលស្រុកបរសេដ្ឋ វាផ្លាស់២-៣ដំណាក់វាផ្លាស់ស្រុក វាចែកស្រុកល្អិត ។

ធានី ៖ តំបន់នឹងនារសាគេធ្វើអីគេ?

រី ៖ ចេញពីនារសាទៅជីកប្រឡាយ ជីកទំនប់ ។

ធានី ៖ នៅតំបន់នឹង?

រី ៖ នៅតំបន់នឹងអត់មានធ្វើអីទេ នៅដល់យើងជីកប្រឡាយជីកទំនប់ជំនាន់នឹង ។

ធានី ៖ ហើយកាលនឹង អ្នកណាគេប្រធានឃុំនៅនឹង?

រី ៖ អូ! ភ្លេចហើយ ។

ធានី ៖ ចុះប្រធានតំបន់?

រី ៖ ប្រធានតំបន់ពូសុខ គាត់ប្រធានតំបន់ ប៉ុនយើងអត់បាននៅជាមួយគាត់ នៅតាមផ្នែកផ្សេងទៀត ចង់និយាយអីចឹង ។

ធានី ៖ ចុះប្រធានស្រុក?

រី ៖ ប្រធានស្រុកមិនដឹងណា ខ្ញុំធ្វើតាមឃុំជំនាន់នោះ ខ្ញុំអត់បាននៅស្រុកផងនៅតែឃុំៗ ហើយឡើងតំបន់ ។

ធានី ៖ មីងនៅនឹងដឹកប្រឡាយ?

រី ៖ ចា៎ស!

ធានី ៖ ម៉េចបានដូរការងារ មីង?

រី ៖ ចុះការងារជំនាន់នោះមានកំណត់ណា ធ្វើការត្រូវធ្វើអីធ្វើទាំងអស់អត់មានរើសអើង អ្នកណាដូចអ្នកណា ។

ធានី ៖ ខាងណាអ្នកចាត់ចែងឲ្យធ្វើអីចឹង?

រី ៖ ជាទូទៅគ្រប់កន្លែង ឲ្យតែត្រូវការមានប្រឡាយ មានទំនប់ គេដឹកហើយយើងកម្លាំងដឹកដែលដឹក ។ ជំនាន់នោះចេញពីនឹងមកគេហៅចេញមកពីនឹងមកចូលអង្គភាពៗក្រសួងមន្ទីរក៏យើងដឹកអត់ ចៀសវាងតែកងទ័ពយោធាអត់ដឹក ជំនាន់នោះយើងសង្គ្រាម ។

ធានី ៖ មីងមិនមែននៅក្នុងកងទ័ពយោធាទេ?

រី ៖ អត់ទេ ។

ធានី ៖ មីងក្រោយមកថា?

រី ៖ នៅយើង៧៩ ដែលមកពីនោះមកដល់នេះ និយាយពី៧៩យើងរត់មកក្នុងព្រៃហើយ ដឹកជញ្ជូន នៅជាមួយទ័ព មិនមែនយើងកងទ័ព យើងដឹកជញ្ជូន ។

ធានី ៖ មីងកាលពេលនៅតំបន់៣៣ដឹកប្រឡាយ ដល់ពេលក្រោយមកធ្វើអីទៀត?

រី ៖ មកនៅជាមួយអង្គភាពយោធាក៏ដឹកប្រឡាយ នៅអង្គភាពយោធាៗជំនាន់នឹងយើងឈប់វៃដូច៧៥ ក៏យើងដឹកប្រឡាយទៀត ។

ធានី ៖ ១៩៧៥នៅដឹកប្រឡាយដដែល?

រី ៖ ហ្នឹងហើយ គេវៃផ្នែកក្រសួងមន្ទីរក៏យើងដឹកប្រឡាយនៅតាមជនបទ គេនៅភ្នំពេញគេធ្វើការងារផ្សេង យើងនៅជនបទធ្វើផ្សេង ដូចយើងឥឡូវអីចឹងនៅភ្នំពេញធ្វើអី នៅជនបទធ្វើស្រែចំការ វាមានមុខជំនាញខុសៗគ្នា ។

ធានី ៖ កាលពេលមីង៧៥ធ្វើដឹកប្រឡាយ?

រី ៖ ហ្នឹងហើយ ។

ធានី ៖ នៅណាវិញ?

រី ៖ ដីកនៅមុំយើងកោះផ្ទូវ គេហៅទំនប់ទួលថ្មី ទួលល្ពាមុំ៥៥តាកែវដែរនឹង ។

ធានី ៖ មីងកំពង់ស្ពឺផង នេះផង?

រី ៖ នៅអង្គភាពជិនាន់នោះយើងអត់កំណត់បានទេ តែគេចាត់តាំង យើងអត់មានផ្ទះសម្បែងទេ ។

ធានី ៖ ៥៥ហ្នឹងអីគេ?

រី ៖ ស្រុក៥៥ស្រុកព្រៃកប្បាស ហ្នឹងហើយពីដើមគេប្រើលេខ ស្រុក៥៥ស្រុកព្រៃកប្បាសឥឡូវ ។

ធានី ៖ កាលមុនមីងនៅកំពង់ស្ពឺ ម៉េចបានទៅដល់ស្រុក៥៥?

រី ៖ រឿងនឹងយើងមិនអាចកំណត់បាន ព្រោះយើងអង្គភាព ។

ធានី ៖ អង្គភាពអីគេ?

រី ៖ អង្គភាពតំបន់គេផ្លាស់ម៉ាតំបន់៣៣នឹងមានអង្គភាព និយាយរួមអង្គភាពមានការផ្លាស់ប្តូរអត់មាន កំណត់បានទេ យើងអ្នកដើរធ្វើការ ។

ធានី ៖ អង្គភាពគេហៅអង្គភាពអី?

រី ៖ អង្គភាពតំបន់ ។

ធានី ៖ គេហៅអង្គភាពតំបន់?

រី ៖ ចាំ!ហ្នឹងហើយតំបន់៣៣ ប៉ុនគេដកយើងទៅនេះទៅនោះស្រេចគេ ។

ធានី ៖ មីងធ្វើអីគេនៅក្នុងអង្គភាពនឹង?

រី ៖ ខ្ញុំអត់មានធ្វើអីទេ នៅកងសមាជិកគេ គេឲ្យធ្វើអីធ្វើនឹង ។

ធានី ៖ មីងជាកូនសមាជិកក្នុងអង្គភាពតំបន់នឹង?

រី ៖ ចាំ! មានគេធំជាងយើង ប៉ុនយើងសមាជិកគេ ។

ធានី ៖ សមាជិកយ៉ាងម៉េច?

រី ៖ ខ្ញុំសមាជិកប្អូនឯងក្រុម ខ្ញុំកូនក្រុមប្អូនឯង ឧទាហរណ៍ ។

ធានី ៖ សមាជិកនឹងមានប៉ុន្មាននាក់?

រី ៖ ម៉ាក្រុមនឹងមាន១២នាក់ ។ ក្នុងម៉ាកងតូចមាន៣០-៣៥នាក់ រដ្ឋពីដើមហៅម៉ាកងតូច ។

ធានី ៖ ម៉ាកងតូច៣០ប៉ុន្មាន?

រី ៖ ៣២-៣៣តាមកម្លាំងចំនួនច្រើន ។

ធានី ៖ ដល់ពេលក្រុម១២?

រី ៖ ចាំ!

ធានី ៖ ហើយអីទៀត?

រី ៖ ហ្នឹងហើយយើង ។

ធានី ៖ ហើយម៉ាក្រុម១២គេធ្វើស្អី កងតូចធ្វើស្អី?

រី ៖ អានឹងគេរៀបជាកង ជាអង្គភាព ។

ធានី ៖ ម៉ាអង្គភាពមានប៉ុន្មានកងតូច ប៉ុន្មានកងធំ?

រី ៖ ម៉ាអង្គភាពនឹងច្រើនណាស់ ប៉ុនយើងនិយាយម៉ាកងតូចយើងមួយនឹងវាមាន ម៉ាកងតូចវាមាន ៣៦-៣៧តាមនឹងមានមនុស្សតិចច្រើន វាមិនកំណត់ ។

ធានី ៖ មីងនៅក្នុងកងណា កងតូចឬកងធំ?

រី ៖ អូ! ចាំមិនបានទេ វាយូរពេកហើយ ។

ធានី ៖ មីងជាសមាជិកនៃអង្គភាពតំបន់នឹង?

រី ៖ ចា៎ស! សមាជិកអង្គភាពតំបន់ ។

ធានី ៖ គេហៅអីចឹង?

រី ៖ ចា៎ស!

ធានី ៖ ចុះអ្នកណាជាប្រធានអង្គភាពតំបន់?

រី ៖ វាច្រើនផ្នែកតំបន់មួយៗវាមានផ្នែកនេះផ្នែកនោះ ។

ធានី ៖ អ្នកណាជាមេរបស់មីងនៅក្នុងផ្នែកអី?

រី ៖ ជំនាន់នោះវាយូរពេកហើយ ភ្លេចហើយតាំងពីជំនាន់ឆ្នាំ៧០-៧១ មិនអាឡូអាឡាទេ ។

ធានី ៖ ៧៥មីងធ្វើអី?

រី ៖ ខ្ញុំ៧៥ ខ្ញុំនៅកងចល័ត ។

ធានី ៖ កងចល័តណា?

រី ៖ កងចល័តតំបន់ហ្នឹងឯងនៅតំបន់ជាមួយគ្នារបូត ៧៣ ៧៤ក៏នៅកងដែរ ។

ធានី ៖ កងដដែល?

រី ៖ ចា៎!

ធានី ៖ ដល់៧៥ក៏នៅកងដែរ?

រី ៖ ចា៎!

ធានី ៖ ធ្វើអីគេនៅកងដដែល?

រី ៖ ធ្វើស្រែជីកប្រឡាយជាមួយគ្នានឹង ត្រូវការជីកប្រឡាយៗ ខែប្រាំងជីកប្រឡាយខែវស្សាឡើងធ្វើស្រែទៅ ការងាររអត់កំណត់ដូចឯកជនណាធ្វើការងាររួម ។

ធានី ៈ ចុះកាលនឹងអត់ដីកប្រឡាយនៅណា ធ្លាប់លើកទំនប់?

រី ៈ លើកទំនប់ដូចខ្ញុំថា នៅទួលថ្មីលង្កានឹងឯង នៅតាកែវ ។

ធានី ៈ ទំបន់ធំទេ?

រី ៈ ហ៎! មិនដឹងម៉េចទេ ជំនាន់នឹងទំនប់គេធំនឹងឯង កាត់ពីអង្គរបូរីទៅធ្លាយដល់កំពង់អំពិល កំពង់យោល ប៉ុនឥឡូវមិនដឹងម៉េច បើខ្ញុំចេញតាំងពី៧៩ដែរ មិនដឹងរបៀបរបបម៉េចទេ ។

ធានី ៈ កាលជំនាន់នឹងមីងយល់ថាធំទេ?

រី ៈ គេលើកទំនប់ធំណាស់ ខ្ពង់គេ២០ម៉ែត្រខ្ពង់លើ ។

ធានី ៈ ពីក្រោមទៅលើ២០ម៉ែត្រ?

រី ៈ ចា៎! ទាយមិនដឹងកំពស់ប៉ុន្មានទេ ប៉ុនត្រឹមខ្ពង់លើផុតទឹក ប៉ុនឥឡូវដឹងម៉េចបើខ្ញុំលើកតាំងពីជំនាន់នោះ ចោលកន្លែងអង្គភាពនឹងវាយូរហើយ ។ អានេះធ្វើមិនកំណត់អង្គភាពខ្ញុំ ។

ធានី ៈ អង្គភាពមីងគ្រប់គ្រងទំនប់ទួលលង្កាទេ?

រី ៈ ចា៎!ហ៎!ដើរតែពាស ហៅចេញពីនឹងទៅកំពង់សោម ចេញពីកំពង់សោមមកភ្នំពេញ មិនកំណត់ទេការងារ ។

ធានី ៈ កាលនឹងទៅកំពង់សោមធ្វើអីគេ?

រី ៈ ទៅធ្វើចំការកៅស៊ូបាន៣ខែ ។

ធានី ៈ ឆ្នាំប៉ុន្មាន មីងចាំទេ?

រី ៈ ឆ្នាំ៧៦ ចាប់ពីខែ១ដល់ខែ៤មកវិញ ។ បើយើងការងារប៉ុននឹងហើយ មានអីដល់ទៅធ្វើ ។ ដល់ពីនឹងមកចេញមកនៅភ្នំពេញ ឆ្នាំ៧៦ខែ៤ចេញមកនៅភ្នំពេញវិញ ។

ធានី ៈ កំពង់សោមធ្វើចំការកៅស៊ូ ធ្វើអីខ្លះ?

រី ៈ ធ្វើស្មៅ ជាជ័រតាមការងាររបស់យើងគេឲ្យយើងធ្វើជំនាន់នឹង ។

ធានី ៈ ចំការកៅស៊ូនៅកំពង់សោម?

រី ៈ ចា៎!

ធានី ៈ បន្ទាប់មកខែ៤ ៧៦មីងមកភ្នំពេញធ្វើអីគេ?

រី ៈ នៅរោងចក្រ ។

ធានី ៈ រោងចក្រធ្វើអីគេ?

រី ៈ រោងចក្រក្រឡឹងដែក ។

ធានី ៈ ក្រឡឹងដែកនៅណា?

រី ៖ នៅគីឡូលេខ១០ នៅជិតព្រែព្នៅ មកពីឫស្សីកែវមក ពាក់កណ្ដាលឫស្សីកែវ ពាក់កណ្ដាលព្រែកព្នៅនឹងឯង ។

ធានី ៖ ហើយនៅកន្លែងរោងចក្រនឹងធ្វើក្រឡឹងដែកធ្វើអី?

រី ៖ ក្រឡឹងដែកគេធ្វើគ្រឿងម៉ាស៊ីន គ្រឿងបាឡុងផ្សេងៗក្នុងអង្គភាព មិនដឹងយកទៅណាទេប៉ុននៅក្រឡឹងដែកនៅនឹងឯង ក្រឡឹងគ្រឿងម៉ាស៊ីនតំឡើង ។

ធានី ៖ មីងក្រឡឹងខ្លួនឯង តំឡើង?

រី ៖ អត់ទេ អង្គភាពជារួម ។

ធានី ៖ មីងនៅផ្នែកណាមួយ?

រី ៖ ហ្នឹងហើយ នៅផ្នែកក្រឡឹង ។

ធានី ៖ មីងក្រឡឹងខ្លួនឯង?

រី ៖ ក្រឡឹងខ្លួនឯង អង្គភាពផង ជារួមតាមការណែនាំរបស់គេឲ្យធ្វើ ។

ធានី ៖ មីងក្រឡឹងបានដែរ ដែកធំៗ?

រី ៖ ដែកធំៗយើងក្រឡឹងបាន អាដែកធំមានផ្នែកគេផ្សេង ។

ធានី ៖ មីងក្រឡឹងបាន?

រី ៖ យើងក្រឡឹងដែកតាមផ្នែករបស់យើង ក្រឡឹងដែកប៉ុនកដៃ ប៉ុនកជើងតាមជំនាញគេឲ្យក្រឡឹង ។

ធានី ៖ ហើយមីងនៅមុខជំនាញអីគេ?

រី ៖ ខ្ញុំផ្នែកក្រឡឹង ។

ធានី ៖ ហើយមីងធ្វើជាអីគេនៅក្នុងនឹង?

រី ៖ យើងផ្នែកក្រឡឹងខាងប្រធានផ្នែក ។

ធានី ៖ ហៅប្រធានផ្នែកក្រឡឹង?

រី ៖ ចាំ!

ធានី ៖ មីងធ្វើការខ្លួនឯង?

រី ៖ ធ្វើខ្លួនឯងក៏ធ្វើ កូនក្រុមក៏ធ្វើៗទាំងអស់គ្នាមិនមែនតែយើងណា ។ គ្រាន់មានប្រធានមួយវាគ្រប់គ្រងកូនសមាជិកនៅក្នុងក្រុមនឹងឯង ។

ធានី ៖ ផ្នែកក្រឡឹងនឹងមានកូនក្រុមប៉ុន្មាននាក់?

រី ៖ កូនក្រុមម៉ាកង ម៉ាអង្គភាពស្រី៣០ ហើយ៤០វាក្មេចហើយវាបែកគ្នា ។

ធានី ៖ តែស្រីៗ?

រី ៖ ស្រីក៏មាន ប្រុសក៏មានចំរុះគ្នាអង្គភាព ។

ធានី ៖ ជាធម្មតាសម័យឥឡូវជំនាន់ហ្នឹងគេច្រើនប្រុស?

រី ៖ ចា៎! ចំនួនស្រីហើយនឹងប្រុសស្មើគ្នា ។

ធានី ៖ ចុះផ្នែកផ្សេងៗទៀត?

រី ៖ ផ្នែកផ្សេងក៏មានដូចតែគ្នា អ្នកណាក្រឡឹងៗអ្នកណាតំឡើងៗ ។

ធានី ៖ គេធ្វើអីគេនៅកន្លែងនឹង តំឡើងអី ក្រឡឹងអី?

រី ៖ ម៉ាស៊ីនបោកជំនាន់នោះ ជ្រលក់អំបោះអីតាម មិនទាន់បានតំឡើងផង ខ្ញុំចូលបាន២ឆ្នាំ ៧៧ ៧៨ ពាក់កណ្តាលឆ្នាំ ៧៧ មក៧៩រត់នៅភ្នំពេញ ។

ធានី ៖ គេឲ្យមីងតំឡើងម៉ាស៊ីនបោក ជ្រលក់អី?

រី ៖ ជ្រលក់អំបោះ ជ្រលក់អី យើងមិនទាន់បានរៀប គ្រាន់តែរៀបគម្រោងធ្វើ មិនទាន់ដំណើរការ ហើយដល់នេះសភាពការណ៍វាប្រែប្រួល ។

ធានី ៖ ប្រែប្រួលផ្សេង?

រី ៖ ហ្នឹងហើយ យើងរត់គាំងពីនឹងមក ។

ធានី ៖ មីងដឹងថាអ្នកណាគេប្រធានរោងចក្រ?

រី ៖ វា២ដំណាក់ ២ដំណ មុនដំបូងអ៊ីឡូន ។

ធានី ៖ អ៊ីឡូននឹងមកពីខាងណា?

រី ៖ ទេមិនដឹងនៅខាងណាអត់សូវស្គាល់ដែរ យើងជំនាន់នោះអត់ ។

ធានី ៖ អត់ដឹងខេត្តណា?

រី ៖ ចា៎! អត់ដឹង ។

ធានី ៖ ប៉ុន្តែដំបូងគាត់ប្រធាន?

រី ៖ ប្រធានរោងចក្រ ។

ធានី ៖ ដល់ក្រោយទៅ?

រី ៖ ដកឡូននឹងចេញទៅ ឈ្មោះ តាំ ។

ធានី ៖ តាតាំប្រធានបន្ទាប់?

រី ៖ ចា៎!

ធានី ៖ ម៉េចបានគេដកអ៊ីឡូន?

រី ៖ ទេ! អត់ដឹងដែរជំនាន់យើងនឹងបត់បែន ។

ធានី ៖ ចុះតាតាំនឹងមកពីណា?

រី ៖ នៅស្រុកណានេះ នៅបស្ទឹមខេត្តកំពង់ស្ពឺខាងជើង មិនដឹងស្រុកអីគេ យើងមិនសូវដឹងអីដែរ ស្រុកផ្សេងៗគ្នា នៅចំរុះរួមគ្នា ។

ធានី ៖ គ្រាន់ដឹងថានៅខេត្តកំពង់ស្ពឺខាងជើង?

រី ៖ ហ្នឹងហើយកំពង់ស្ពឺខាងជើង ។

ធានី ៖ ស្រុកថ្ពង ស្រុកអី?

រី ៖ បែបម៉ាដូរនឹងទេដឹង គ្រាន់ដឹងថានៅនិយាយវៀនវេងិន ។

ធានី ៖ គ្រាន់ដឹងថាគាត់មកពីកំពង់ស្ពឺ បស្ទឹម?

រី ៖ ហ្នឹងហើយ វាចង់ភ្លេចពាក្យហើយនិយាយបស្ទឹម យូរហើយយើងវាខានរំលឹកវា ។

ធានី ៖ កាលនឹងមីងនៅខាងណាវិញ មីងនៅខាងបស្ទឹម ឬខាងណាវិញ?

រី ៖ ខ្ញុំនៅខាងកំពង់ស្ពឺ ។

ធានី ៖ ខាងណា?

រី ៖ កំពង់ស្ពឺខាងជើង?

ធានី ៖ ខាងជើងនឹងគេហៅខាងបស្ទឹម ឬក៏ខាងអីគេ?

រី ៖ អត់ទេ ខាងកំពង់ស្ពឺនេះមិនមែនខាងបស្ទឹមទេ ខាងស្រុកគងពិសីវិញ ។

ធានី ៖ ស្រុកគងពិសីនឹងគេហៅភាគអីគេវិញ?

រី ៖ អានឹងគេហៅភាគនារតី ។

ធានី ៖ ដល់ពេលអ៊ំឡូននឹងមក មីងនៅក្នុងរោងចក្រហើយ?

រី ៖ ចា៎!

ធានី ៖ ដល់ពេលតាតាំនឹងមក ក៏មីងនៅនឹងដែរ?

រី ៖ នៅនឹងដែរ ទើបមកបែកគ្នា៧៩តាតាំនឹង ។

ធានី ៖ ហើយមីងដឹងថាអ្នកណាគេលើធំជាងតាតាំ?

រី ៖ ហ៊ឺ! អត់ដឹងដែរ មានតែអង្គភាពមួយ មានតែគាត់នឹងឯងគ្រប់គ្រងរួមមកប៉ុននឹង ។

ធានី ៖ ម៉ាអង្គភាពធំនឹងមានប៉ុន្មាននាក់?

រី ៖ មិនអង្គភាពប៉ុន្មានទេ បើ១០០នាក់ជាង ខ្ទង់១៣០ អង្គភាពក្រឡឹងតូចដែរ ។ អង្គភាពខ្ញុំតូចទេ មិនដូចអង្គភាពផ្សេងៗ សុទ្ធរាប់ពាន់នោះដូចរោងចក្រតម្បាញជំនាន់ពីដើម ជំនាន់សម័យយើងកសាង ខ្ទះ៥០០-៦០០ ខ្ទះរាប់ពាន់មានច្រើនផ្លាស់ប្ដូរគ្នា ។ តែក្រឡឹងតិចទេ ធ្វើការតែថ្ងៃយប់អត់ធ្វើទេ ។

ធានី ៖ អត់មានការងារច្រើន?

រី ៖ ចា៎! ក្រឡឹងតែថ្ងៃ យប់ឡើងយើងធម្មតា ។

ធានី ៖ ចុះមានថ្ងៃឈប់ ថ្ងៃសម្រាក?

រី ៖ មានថ្ងៃអាទិត្យ ក្នុងម៉ាអាទិត្យឈប់២ថ្ងៃ ថ្ងៃអាទិត្យ-ថ្ងៃសៅរ៍ ។

ធានី ៖ ហើយឈប់ធ្វើអី?

រី ៖ យើងធ្វើចំការ ធ្វើស្រែ ។

ធានី ៖ ធ្វើចំការធ្វើស្រែទៀត?

រី ៖ ធ្វើចំការតាមអង្គភាព ធ្វើស្រែរួមជំនាន់នោះ ។

ធានី ៖ មានចំការមានស្រែ?

រី ៖ មានចំការយើងដាំដំណាំហូបដោះស្រាយជីវភាពតាមអង្គភាព ។

ធានី ៖ ឈប់ ច័ន្ទដល់សុក្រធ្វើការ ថ្ងៃសៅរ៍-អាទិត្យ?

រី ៖ ហ្នឹងហើយសម្រាក ។

ធានី ៖ របៀបសម្រាក?

រី ៖ សម្រាកធ្វើការងារផ្សេង ។

ធានី ៖ ធ្វើការងារផ្សេងក្រៅពីការងារក្រឡឹង?

រី ៖ ចា៎!

ធានី ៖ ធ្វើចំការធ្វើស្រែរាល់ថ្ងៃ?

រី ៖ ចា៎! ដល់ថ្ងៃអាទិត្យ ថ្ងៃសៅរ៍គេសម្រាក ។

ធានី ៖ ចុះបានអីហូប?

រី ៖ ជំនាន់នោះគេបើកឲ្យ បើករបបតាមអង្គភាពអង្គរ ។

ធានី ៖ ហូបរួម ឬហូបតែឯងទេ?

រី ៖ ហូបរួមអត់មានហូបតែឯងទេជារួម អង្គភាពរួម ។

ធានី ៖ មានអីខ្លះហូបទៅ?

រី ៖ មានបាយ មានសម្លដូចយើងឥឡូវ មានម្ហូបម៉ាមុខ២-៣ពេល អត់មានអីទេជំនាន់នោះ ។

ធានី ៖ មីងធ្លាប់ចូលរួមទៅមើលសិល្បៈអីមើលអីគេទេ?

រី ៖ បានមានសិល្បៈស្អាតជំនាន់នោះ ។

ធានី ៖ ចូលបានប៉ុន្មានដង?

រី ៖ ចូលបាន២ដង ។

ធានី ៖ ហើយកាលនឹងម៉េចបានគេឲ្យទៅមើល?

រី ៖ គេរបៀបរបបត្រូវថ្ងៃគេ ដូចថាពួកចិនពួកកូរ៉េគេមកកំសាន្តមកលេងប្រទេសយើងជំនាន់នោះ ។

ធានី ៖ ពួកចិនកូរ៉េម៉េច?

រី ៖ ជំនាន់យើងសម័យនោះមានៗកូរ៉េមកលេង គេឲ្យតាមរោងចក្រទៅមើលៗអ្នកសម្តែងរឿងដូចល្ខោនគេទៅលេងសៀក ។

ធានី ៖ មីងបានមើលអ្នកសម្តែងចិន កូរ៉េនឹងមកសម្តែង?

រី ៖ ចា៎!

ធានី ៖ មកសម្តែង ឬខាងគ្នាយើងសម្តែង?

រី ៖ យើងមិនសម្តែង គេអ្នកសម្តែង ហើយយើងរឿងយើងរឿងគេលេងក៏យើងមើលដូចថាសិល្បៈខ្មែរយើងជំនាន់សម័យនោះ ។

ធានី ៖ បាន២ដង?

រី ៖ ចា៎!

ធានី ៖ កាលនឹងឆ្នាំណាមីងសិល្បៈសម្តែង?

រី ៖ ទេ! ដូចថាវាក្មេចហើយ ៧៧ហ្នឹងឯង បើយើងមកនៅភ្នំពេញ៧៧ហើយ ៧៧ ៧៨ ។

ធានី ៖ មួងនឹងម៉ាឆ្នាំ ២ដងនឹង?

រី ៖ អត់ទេ វាមានម៉ាឆ្នាំមួង ដូចថាវាមានថ្ងៃបុណ្យកំណើត បុណ្យអីរំលឹកយើងបានទៅមើល ដូចជាកម្មវិធីបុណ្យជំនាន់នោះ ។

ធានី ៖ មីងថានៅនឹងរហូតដល់៧០ប៉ុន្មានបានមីងរត់?

រី ៖ នៅ៧៩បានចេញពីភ្នំពេញមក ។

ធានី ៖ គេប្រាប់ថាម៉េចបានចេញ?

រី ៖ គេប្រាប់ថាឲ្យដកម៉ារយៈ ។

ធានី ៖ ខាងណាមកប្រាប់?

រី ៖ អង្គភាព មេអង្គភាពជារួមគ្រប់ក្រុម ដឹងខាងណាខ្ញុំមិនសូវដឹងដែរ យើងតូចតាចជាងគេ ។

ធានី ៖ ម៉ារយៈនឹងដកទៅខាងណា?

រី ៖ ហ្នឹងឯង ចេញមកពីភ្នំពេញបាត់ដំបងនឹងឯង ។

ធានី ៖ បន្ទាប់មកទៀតម៉េចដែរ?

រី ៖ មានហូបគ្រប់គ្រាន់ តាមផ្លូវអង្គការខបត្ថម្ភគ្រប់គ្រាន់ ។

ធានី ៖ មីងហូបគ្រប់គ្រាន់រហូត?

រី ៖ ចា៎! ហ្នឹងហើយ ប៉ុនគ្រាន់ឈើថ្កាត់បន្តិចយើងរត់កាត់ព្រៃកាត់ផ្សេ វាមានជម្ងឺមានមុងមានអីដេក សមរម្យទេ ប៉ុនគ្រាន់ថាជីវិភាពហួបចុកអីវាមានពេលខ្វះមានពេលមាន មិនមែនហូបគ្រប់របួត ។ ជំនាន់នោះរត់មានអ្នកណាដឹកស្បៀងតាម ប៉ុនមិនដាច់ពេល វាមានហូបគ្រប់គ្រាន់ម៉ាសមរម្យលាយ ។

ធានី ៖ កាលពេលមីងរត់មក រត់ជាមួយអង្គភាពរបស់មីងដដែល?

រី ៖ អត់ទេ ចំរុះគ្នាលែងមានអង្គភាពហើយ ។

ធានី ៖ បែកបាក់គ្នាអស់ហើយ?

រី ៖ ចា៎! រត់តែអង្គភាពស្រី អង្គភាពប្រុសវានៅរោងចក្រវារត់ផ្សេង បែកគ្នាជំនាន់នោះ ។

ធានី ៖ តែមីងអ្នកដឹកនាំរត់ទៅ?

រី ៖ មកជាមួយគេ ។

ធានី ៖ មកជាមួយអ្នកណាគេ?

រី ៖ ជាមួយអង្គភាពចំរុះគ្នា ដូចថាអង្គភាព មិនមែនរត់តែអង្គភាពយើងរត់ទេជំនាន់នោះវាច្រើន អង្គភាពយើងចេះមកជាមួយគេមក ។ អង្គភាពយើងគ្នា៣០នាក់ ៤០នាក់ស្រី គេស្រីរត់មក មានអង្គភាពផ្សេងចេះតែជិះរទេះភ្លើងឡើងចំរុះគ្នា អត់មានគិតនេះនោះទេ គិតរឿងរត់ម៉េចឲ្យបានរួចខ្លួនចេញពីភ្នំពេញជំនាន់នោះ ។

ធានី ៖ ចេះរត់សិនទៅ ទៅដល់ណាបានចាប់ផ្តើមមានអង្គភាព?

រី ៖ រៀបរយអង្គភាពឆ្នាំចូល៨១បានមានអង្គភាព យើងរៀបរយតាមអង្គភាពមកនៅព្រំដែនយើង កកើតជាដឹកជញ្ជូនអង្ករដាក់ឃ្លាំង ។

ធានី ៖ កាលពេលនឹងមីងមកនៅម៉ាឡៃជំបូងឥឡូវ?

រី ៖ ហ្នឹងហើយមកដល់ម៉ាឡៃជំបូង មិនទាន់រៀបរយម៉ាឡៃជំនាន់នឹង នៅក្នុងព្រៃមិនទាន់ដាក់ឈ្មោះ មិនទាន់មានស្រុកមានឃុំអីទេ ជំនាន់ ។

ធានី ៖ ចេះនៅក្នុងព្រៃសិន?

រី ៖ ចេះនៅដឹកជញ្ជូន ដឹកអង្ករចូលឃ្លាំង ចូលជង្រុកអីនឹង ។

ធានី ៖ ពេលនៅព្រៃអត់ទាន់កកើត នៅជាម៉េច?

រី ៖ នៅជាអង្គភាព ប៉ុនអង្គភាពរួមដូចថាមានធុរះដូចរៀបជាអង្គភាពដឹកជញ្ជូន ។

ធានី ៖ មីងថានៅជំបូងអត់មានជាអង្គភាពមានជាអីទេ?

រី ៖ រត់មកតាមផ្លូវអត់ទាន់មានទេ ចំរុះ ដល់ជុំគ្នា គេរៀបរយជាអង្គភាព ។

ធានី ៖ មកដល់ព្រៃនឹង?

វី ៖ មកដល់កន្លែងនឹងនៅសមរម្យ ។

ធានី ៖ មកដល់យូរហើយបានរៀបជាអង្គភាព?

វី ៖ ចា៎! ចេះរត់ម៉ាអង្គភាព១ ចេះចំរុះគ្នា យើងទើបរៀបរយជាអង្គភាពនៅ ពីមុនអង្គភាពចំរុះ ចេះស្គាល់គ្នាចេះនៅយើងស្គាល់គ្នាពីមុនមកចេះរត់ធ្វើម៉េចម៉ារស់រៀងខ្លួន ចាប់រៀបរយអង្គភាពកកើតដឹកជញ្ជូន ។

ធានី ៖ កកើតឆ្នាំប៉ុន្មាន ដែលចាប់ផ្ដើមរៀបអង្គភាព?

វី ៖ រត់ចេញ៧៩មក មកជួបគ្នានៅត្រាង ចំការចេកនេះឯង ម៉ាអង្គភាពចំរុះគ្នា ឥឡូវបែកគ្នាអស់ហើយ នៅតែខ្ញុំ២-៣នាក់ជុំគេ ពីមុនគេនៅជាក្រុមជាកង ឥឡូវបែកគ្នាអស់ហើយ នៅជាភូមិវិញ ។

ធានី ៖ កាលមុនមីងនៅជុំគ្នាដំបូងនៅត្រាង បង្កើតជាអង្គភាពមួយ?

វី ៖ ហ្នឹងហើយ ។

ធានី ៖ ហើយអ្នកណាគេអ្នកផ្ដួចផ្ដើមបង្កើតអង្គភាពនឹង ដែលក្រុមមីងកុំអាលនិយាយក្រុមគេ?

វី ៖ ក្រុមខ្ញុំមានកាលនឹងភី និយាយរួមមានវរសេនាធំគ្រប់គ្រងតាមជាន់ថ្នាក់ ។

ធានី ៖ វរៈសេនាធំនឹងអ្នកណាគេ?

វី ៖ អូយ! ច្រើនចង់ភ្លេចអស់ហើយ វាយូរពេកហើយជំនាន់នោះ ប៉ុនវារៀបតាមថ្នាក់តាមជាន់ពីលើមកវាឲ្យរៀបជាកងជាក្រុមជាពួកផ្នែកដឹកជញ្ជូនមាន៣-៤ផ្នែក ។

ធានី ៖ មីងនៅផ្នែកអីគេ?

វី ៖ ខ្ញុំនៅដឹកជញ្ជូន បងខ្ញុំក៏នៅដឹកជញ្ជូន ប៉ុនមនុស្សវាច្រើនគេរៀប៣-៤កង ។

ធានី ៖ ម៉ាកងមានផ្នែកដឹកជញ្ជូនមួយ?

វី ៖ ម៉ាកងដឹកជញ្ជូន កងផ្សេងក៏ត្រូវដឹកជញ្ជូនដូចគ្នា ។

ធានី ៖ ដឹកជញ្ជូនដូចម៉េច គេមិនត្រូវចែកគ្នាដើម្បីធ្វើ?

វី ៖ ដូចថាវាមានវេណដឹកជញ្ជូន ដូចថាថ្ងៃនេះខ្ញុំ ស្អែកឡើងប្អូនឯង ឧទាហរណ៍ ។

ធានី ៖ បានន័យថាម៉ាកងដឹកជញ្ជូនមីងមិនមែនមានតែម៉ាកងទេ មាន៣-៤កង?

វី ៖ មាន៣-៤កងច្រើនណាស់ ។ ម៉ាវរសេនាធំ មាន៣វរសេនាតូចវាច្រើន ។

ធានី ៖ វរសេនាតូចលេខប៉ុន្មាន វរសេនាធំលេខប៉ុន្មាន?

វី ៖ ភ្លេចហើយយូរហើយ មិនចាំ ។

ធានី ៖ ម៉ាកងមីងនៅវរសេនាណា?

រី ៈ ក្មេងទាំងឈ្មោះ ក្មេងទាំងកងមិនបានគិតគូរទេ ។ តែដឹងថាម៉ាវរសេនាធំមានពាកងមានច្រើន ក្មេងហើយមិនបានគិតគូរឿងក្មេងវាហត់ហាវពេក ។

ធានី ៈ មីងនៅកងដឹកជញ្ជូនណា?

រី ៈ ខ្ញុំនៅកងដឹកជញ្ជូនក្មេងឈ្មោះទៀតហើយ មិនបានគិតគូរការងារថាវាយូរពេកហើយ មិនបានចាប់អារម្មណ៍វាក្មេងលេខប៉ុន្មានទេ ។

ធានី ៈ ដូចថាអ្នកណាគេអ្នកផ្ដួចផ្ដើមឲ្យប្រមូលផ្ដុំជាកងជាក្រុម?

រី ៈ ក្មេងទាំងមនុស្សក្មេងទាំងចំនួន វាយូរពេកហើយ មិនបានចាំការងារ យើងដូចថាវាម៉ាដំណាក់ៗកាលមិនបាន ហើយវាលែងគិតគូ ។

ធានី ៈ ពេលដែលគេរៀបកងហើយអ្នកណាគេអ្នកផ្ដួចផ្ដើមឲ្យបង្កើតចេញជាស្រុកម៉ាខ្សែ?

រី ៈ មកនៅតាមអគ្គភាពយោធា ដូចថាប្អូនៗគេគ្រួសារគេយើងមកនៅជាមួយគេនៅតាមអគ្គភាព ។ ពីមុនមាននៅតាមកងដឹកជញ្ជូនជុំគ្នា ដល់ប្អូនណាមានប្ដីមានសី យើងនៅតាមកងយោធា រៀបជាផកងដល់ឥឡូវកើតជាភូមិ វាបែកច្រើនដំណាក់ច្រើនដំណពិបាកចាំ ។

ធានី ៈ ដំបូងមីងថានៅជាកង?

រី ៈ ហ្នឹងហើយ នៅជាកង ។

ធានី ៈ ឆ្នាំប៉ុន្មានដែរ?

រី ៈ កងដឹកជញ្ជូននៅពីឆ្នាំ៧៩ ៨៣ ៨៤ ៨៥បានចេញ ។

ធានី ៈ ចេញទៅណាវិញ?

រី ៈ ចេញមកនៅតាមអគ្គភាពយោធាប្អូនមានប្ដីមកនៅជាមួយគេ ។

ធានី ៈ ៧៩មកនេះ កង?

រី ៈ ហ្នឹងហើយកងដឹកជញ្ជូនប៉ុន្មានឆ្នាំ តាំងពី៧៩ដល់៨៥បានឈប់ដឹកជញ្ជូន ។

ធានី ៈ ម៉េចបានមីងឈប់?

រី ៈ ចុះយើងចាស់ដង វាណើយណាយដង យើងចាស់ដង នៅការងារក្រោយ ។

ធានី ៈ មីងចេញពី៨៥ បន្ទាប់មកឈប់ធ្វើកង ធ្វើអីវិញ?

រី ៈ មកនៅតាមភូមិយើងអីចឹង រៀបសេនាជនភូមិ ។

ធានី ៈ មីងមកនៅ៨៥នៅនឹង?

រី ៈ អត់ទេ នៅ៨៥នៅដីថៃ ។

ធានី ៈ ម៉េចបាននៅដីថៃ?

វី ៖ ចុះយើងរត់ជំនាន់នោះ យើងមិនមែននៅជាប់ព្រំដែន បើយួនវ៉ៃបុកព្រំដែន យើងមិនរត់ទៅដីថៃ។ នៅ៨៥ ៗ គេហៅដីថៃ មិនមែនដីយើងនេះទេ ។

ធានី ៖ ហើយនៅ៨៥ នៅកន្លែងណាទៅ?

វី ៖ អត់ស្គាល់ នៅស្រុកថៃជ្រៅដែរ ។

ធានី ៖ ពីនឹងទៅប្រហែលប៉ុន្មានគីឡូ?

វី ៖ ជិះពីនឹងនៅ៣-៤ម៉ោង មិនដឹងណាយើងអត់ដែរដើរ ។

ធានី ៖ ហើយបន្ទាប់មកទៀត បានមីង?

វី ៖ ហ្នឹងហើយឈប់ដឹកជញ្ជូនមក យើងមកនៅអង្គភាពតាមយោធា យើងដឹកជញ្ជូនលែងកើតយើងចូលសមាគមន៍ ។

ធានី ៖ សមាគមន៍នៅខាងណាវិញ?

វី ៖ សមាគមន៍នៅអង្គភាពនឹងដដែល សមាគមន៍ដូចថាយើង ៗ សមាគមន៍ជួយគ្នាទៅវិញទៅមក ពេលឈឺថ្កាត់ ពេលអ្នកសម្រាលអ្នកអីប្តីមិននៅទៅសមរភូមិ រៀបចំសមាគមន៍ជួយគ្នា ។

ធានី ៖ មីងជួយអ្នកដែលសម្រាលកូន?

វី ៖ ហ្នឹងហើយ ។

ធានី ៖ គ្រាន់ជួយបានជាគ្នា?

វី ៖ ជួយថែជួយមើល មានគេអ្នកដេរ្យងអ្នកសម្រាល ប៉ុនជួយមើលថែអ្នកសម្រាល ។

ធានី ៖ ហើយបន្ទាប់មកទៀតម៉េចមីង?

វី ៖ នៅ៨៥នឹង ដល់យើងឆ្នាំ៩១ឡើងពីនេះមកវិញ ។

ធានី ៖ មីងនៅពី៨៥ដល់៩១?

វី ៖ ចា៎! ឡើងមកដីយើងដេញយួនអស់ពីទឹកដីយើងមកវិញ ពីមុនម៉ាជួរនេះវាព្រៃហើយ យួនមកនៅឈរជើង ។

ធានី ៖ យួនមកនៅនេះដែរ?

វី ៖ ចា៎!

ធានី ៖ មីងមកនៅនឹងម៉េចដែរ ពេលមកវិញ?

វី ៖ មកដល់វាដីព្រៃ វាអត់មានវាលទេ យើងកាប់ឆ្ការធ្វើភូមិនៅ ហើយក៏យើងចេះវាទបានជាដីស្រែធ្វើស្រែនៅ ។

ធានី ៖ ហើយធ្វើស្រែហូបខ្លួនឯង ឬក៏រួម?

រី ៖ អត់ទេ ហូបតាមក្រុមគ្រួសារ ធ្វើបានប៉ុន្មានហូបខ្លួនឯង កាប់បានដាំកូនសណ្ដែកមានចិនទិញក៏លក់ទៅ ។ យើងនៅជាប់ថៃលក់ឲ្យថៃ គេត្រូវហូបទៅសល់ពីហូបក៏យើងលក់ដូចសព្វថ្ងៃ ជំនាន់នោះឡើងមកដល់ដីយើង ធ្វើឯកជនអត់មានរួម ។

ធានី ៖ អត់មានមីនមានអីទេ?

រី ៖ មានៗមីន ។

ធានី ៖ មីនពីណាមកវិញ?

រី ៖ មានមីនយើងក៏ដាក់ទាហានខ្មែរជំនាន់នោះហៅកម្ពុជាប្រជាធិបតេយ្យទ័ព ខ្ញុំមិនសូវប្រសព្វហៅ យើងក៏ដាក់ការពារខ្មាំង គេក៏ដាក់ការពារយើងដាក់ទាំងសងខាងជំនាន់នោះណា ។

ធានី ៖ ដាក់ខាងណា?

រី ៖ ដាក់ដីយើងអស់នឹង ឲ្យតែដាក់ទុកតែចន្លោះផ្លូវដើរហ្នឹងការពារទាំងអស់គ្នាយើងក៏ដាក់គេក៏ដាក់ ។

ធានី ៖ មីងមកវិញសុទ្ធតែមីន?

រី ៖ មីន វាចន្លោះខ្វះមិនដាក់ពេញទេ ដូចថាកន្លែងណាបន្ទាយគេដាក់ការពារបន្ទាយយើងក៏ដាក់ការពារភូមិយើងទៅ កាល មិនទាន់រត់យួន៨៥ ។

ធានី ៖ មីងដាក់ដែរ?

រី ៖ អត់ទេ យោធាគេអ្នកដាក់ទេ គ្រាន់យើងប្រជាជននៅអគ្គភាព ។ ដូចថាកន្លែងណាមានមីន គេដាក់តំរុយថាមីន យើងអត់ហ៊ានចូល ប្រាប់គ្នាយើងអគ្គភាពយើងមុខសញ្ញាដាក់តំរុយអីមួយឲ្យយើងដឹង ។

ធានី ៖ ដល់ពេល៨៥ហើយមកវិញ?

រី ៖ មកវិញ មីនកន្លែងមានមីនយើងមិនហ៊ានធ្វើទុកឲ្យគេដោះ អ្នកខ្លះគេចេះដោះគេចេះរាវធ្វើចំការធ្វើស្រែ ។

ធានី ៖ មីងអត់ហ៊ានធ្វើទេ?

រី ៖ ចា៎!

ធានី ៖ មីងអត់ហ៊ានកាប់ចំការ ចាំមើលគេ?

រី ៖ ហ្នឹងហើយ យើងធ្វើទៅសួរគេ កន្លែងណាដែលមានមីនឬមិនមានមីន ។

ធានី ៖ មីងធ្វើខ្លួនឯងដែរ?

រី ៖ ចា៎! កាប់ចំការបាន ។

ធានី ៖ រាវខ្លួនឯងដែរ?

រី ៖ អត់ទេ មិនរាវទេ គ្រាន់កាប់ទៅសួរគេថាកន្លែងនឹងអត់អី យើងសុំគេធ្វើត្រង់នឹង យើងចាប់ខ្លួនយើងធ្វើ ។

ធានី ៖ ដីកន្លែងណាអត់មាន?

រី ៖ ចា៎! ចុះយើងសួរគេមិនមែនទឹកដីយើងណា ពីមុនខ្ញុំនៅត្បូង ខ្ញុំមកនៅឡើងមកនេះយើង៩១ ។ យើងធ្វើម៉ាហូបៗ បើថាយើងធ្វើភូមិនៅក្បែរផ្ទះសួរគេទៅកន្លែងណាអត់មីនយើងចេះវាទដីភូមិនៅ ។

ធានី ៖ ការស្នាក់នៅម៉េចដែរ ជំនាន់នឹងសុទ្ធតែព្រៃស្នាក់នៅណា កាលមីងនៅអន្លុងភាព?

រី ៖ នៅអន្លុងភាព ព្រៃធំយើងកាប់ធ្វើជំរកខ្លួនយើង ក្រងស្បូវជំនាន់នោះ ។

ធានី ៖ មានស្បូវក្រងដែរ?

រី ៖ មានស្បូវយើងប្រូតពីស្រុកថៃមក នៅជាប់ព្រំប្រទល់ថៃ កាលពី៧៩នៅជាប់មាត់អូរព្រំដែនដូចគ្នា ។

ធានី ៖ យើងទៅមកៗ?

រី ៖ ចា៎! ថៃក៏មិនធ្វើអីយើង យើងមិនធ្វើអីវា ។

ធានី ៖ ហើយមីងយកស្បូវមកក្រងធ្វើផ្ទះធ្វើជំរកស្នាក់នៅបណ្ដោះអាសន្ន?

រី ៖ ធ្វើដើមឈើកាប់ធ្វើជំរក ។

ធានី ៖ ដល់ពេលក្រោយទៅ ម៉េចមីងមកនៅផ្ទះកន្លែងនេះ?

រី ៖ ជាច្រើនដំណាក់ច្រើនដំណានិយាយវាវែងឆ្ងាយ យើងមិនមែននៅអន្លុងភាពម៉ាកន្លែងទេ កន្លែងវាច្រើនណាស់នៅនេះតិច នៅនោះតិច ដើរទៅនៅយើងមិនមានកម្មសិទ្ធិអីច្រើនជំនាន់នឹង ។ ទើបមកនៅលំនឹង ត្រឹមត្រូវឡើងពីដីថៃមកដីយើងសារនេះឯងបានមានផ្ទះមានសម្បែង ។

ធានី ៖ បានមីងមក៩១?

រី ៖ ខ្ញុំមក ហ្នឹងហើយ៩១ប៉ុន្នានឡើងមកដីយើង ។

ធានី ៖ ៩១ មីងថាត្រឡប់មកទឹកដីយើង?

រី ៖ ហ្នឹងហើយ គេនាំដាក់គេមានអន្លុងភាពយោធាគេនាំដាក់ ហើយប្រជាជនរៀបជាភូមិនៅតាមមាត់ថ្នល់ ប៉ុនកាលនោះព្រៃពុំមានថ្នល់ចេះទេ ។

ធានី ៖ នៅព្រៃ?

រី ៖ ចា៎! ជាព្រៃ ប៉ុនយើងធ្វើម៉ាជំរកៗនៅចេះកាប់ដាំស្លឹកគ្រៃ ដាំម្ដេងជុំវិញផ្ទះម៉ាហូបៗចេះវាទម៉ាថ្ងៃបន្តិចៗធ្វើតាមយើងធ្វើខ្លាំងក៏ខ្លាចមីន គេថាមិនអីទេកន្លែងនឹងមិនមាន យើងធ្វើទៅក៏អត់មានអីសុខសប្បាយដែរ ។

ធានី ៖ យើងអត់ហ៊ានធ្វើខ្លាំងដែរ?

រី ៖ ហ្នឹងហើយមានទៅធ្វើយកអី ជំនាន់នឹងគេបើកអង្ករឲ្យហូប ។

ធានី ៖ ហូបគ្រប់គ្រាន់ទេ?

រី ៖ ម៉ាគ្រប់គ្រាន់ អង្ករ ម្ហូប ។ ចុះយើងដីព្រៃមានធ្វើអីកើត គ្រាន់វាទុកន្លែងនៅ យើងបើកអង្ករ បើកម្ហូប បើអីសព្វបែបយ៉ាង អំបិល ប្រហុកអីគេមានម៉ាកញ្ចប់ឲ្យ ។

ធានី ៖ ដល់ឆ្នាំប៉ុន្មានបានយើងនៅធម្មតា?

រី ៖ ចូលឆ្នាំប៉ុន្មានហើយទេនេះ ដែលគេឈប់ផ្តាច់ខ្លួនយើងរកស៊ីបានខ្លួនយើងដូចថាដាំដុះអីកើត គេឈប់ខបត្តម្ភនោះ ។

ធានី ៖ ចូលឆ្នាំប៉ុន្មាន?

រី ៖ ចូលឆ្នាំប៉ុន្មានហើយទេ ឆ្នាំ៩៦ ៩៧ គេឈប់ផ្តល់ឲ្យយើងដូចថាយើងដុះដៃជើង យើងចេះដាំបានហូប ស៊ីឈ្នួលថៃបាន គេឈប់ផ្តាច់ឲ្យយើងឈប់បើកឈប់អីទៅ ។

ធានី ៖ ហើយយើងរកស៊ីខ្លួនឯង?

រី ៖ ចា៎! ហ្នឹងឯង រកស៊ីទៅយើងចេះបង្កើតចំការ បង្កើតអីដាំដំណាំលក់បានបន្តបន្ទាប់ យើងធ្វើស្រូវក៏បានហូបខ្លួនឯង ដាំលក់ខ្លះរហូតដលសព្វថ្ងៃ ។

ធានី ៖ មីងថានៅអង្គភាពដឹកជញ្ជូនៗអីគេ?

រី ៖ ដឹកជញ្ជូនអង្ករគ្រាប់អីតាម ។

ធានី ៖ ដឹកពីណាទៅណា?

រី ៖ ដឹកពីដីយើងទៅក្នុងទៀត ដឹកទៅសមរភូមិ ។

ធានី ៖ ទៅសមរភូមិទៅខាងណា បើយើងគិតពីពេលឥឡូវកន្លែងនេះ?

រី ៖ កន្លែងនេះគេហៅកន្លែងដឹកជញ្ជូន ហើយយើងដឹកជញ្ជូនទៅណាថាទៅជងស៊ឹង ឬទៅម្តុំកូនដំរី ឧទាហរណ៍អីចឹង ជំនាន់នោះមិនស្គាល់កូនដំរី ទើបឥឡូវនឹងឯង ឧទាហរណ៍កន្លែងនឹងថាសមរភូមិ យើងឧទាហរណ៍ថាដឹកពីភូមិដូងទៅធ្លាយកូនដំរីកូនអី ។

ធានី ៖ ដឹកមានដឹកគ្រាប់ និងដឹកអង្ករ?

រី ៖ ដឹកអង្ករ ស្បៀងនឹងឯង ។

ធានី ៖ ដឹកពេលណា?

រី ៖ យើងទូលខ្លួនយើង ស្ពាយខ្លួនយើង ។

ធានី ៖ ទូល?

រី ៖ អឺ! លីនឹង-កនឹងឯង ជំនាន់នោះមានអី ។

ធានី ៖ ធូន់ណាស់?

រី ៖ ចុះធ្វើម៉េចទៅតាមដំណើររឿង។

ធានី ៖ ហើយប៉ុន្មាននាក់ទៅកងមីង?

រី ៖ ភាគច្រើនទាំងអស់គ្នាទាំងគេទាំងយើងម៉ាអង្គភាពកងតូច១០នាក់ កងធំ៣០នាក់ ឬ១៥នាក់ តាមជាក់ស្តែង មិនមែនយកច្រើនទេ ម៉ាអង្គភាពវរសេនាធំ១០០នាក់ ឬ១៥០នាក់វាផ្លាស់វេណគ្នាមិនមែនទៅម្តងទាំងអស់ណា ដូចថាប្អូនឯងទៅខ្ញុំមកប្អូនឯងមកខ្ញុំទៅផ្លាស់គ្នា។

ធានី ៖ ឥឡូវមីងរកស៊ីធ្វើចំការធ្វើអី?

រី ៖ ចា៎! ធ្វើចំការស្រែ អត់មានលក់ដូរ។

ធានី ៖ ក្អួយមកនៅមួយ មកពីខាងណាវិញ?

រី ៖ ក្អួយមកពីស្រុកយើងខាងកំពង់ស្ពឺនឹង។

ធានី ៖ មីងដែលធ្លាប់ទៅលេងផ្ទះទេ?

រី ៖ ខ្ញុំទៅៗដាប់ ម្តាយនៅអត់ទាន់អស់បុណ្យទេ។

ធានី ៖ ខស្សាហ៍ទៅលេងគាត់ដែរ?

រី ៖ ចា៎!

ធានី ៖ មីងខស្សាហ៍ទៅលេងគាត់ជួបបងប្អូនចាស់ៗនៅនឹង?

រី ៖ មានអីជួប ពេលយើងទៅលេងចាស់ៗនឹងឯង។

ធានី ៖ ចុះដំបូងពេលមីងអត់ដែលទៅ ម្តាយមីងធ្លាប់ដើររក?

រី ៖ រក។

ធានី ៖ រកដែរ?

រី ៖ ចា៎! គាត់មកជួបខ្ញុំនៅនេះឆ្នាំ៩២ម្តង។

ធានី ៖ គាត់មកដល់នឹង?

រី ៖ ចា៎! គាត់ដើរកាត់ព្រៃពីនឹងមក។

ធានី ៖ មីងទៅយកគាត់នៅណា?

រី ៖ គាត់មកដល់ផ្ទះនឹងឯង ចុះយើងទៅរកណា បើយើងមិនមែនទៅរកគាត់ណា គាត់រកយើង។

ធានី ៖ គាត់រកឃើញដែរ?

រី ៖ សួរស៊ើបសួរតាមគេតាមឯង គាត់មកដល់ផ្ទះយើង ឆ្នាំ៩២កាលគាត់មក។

ធានី ៖ មិនមែនមីងរកគាត់ គាត់រកមីង?

រី ៖ យើងនៅព្រៃជិនាន់នោះ ចាប់ពីពុទ្ធ...មកដល់នេះព្រៃទាំងអស់ កូនដីរីក៏ព្រៃដែរ ទើបវាលឥឡូវ ប្អូនឯងឃើញមកវាលហើយ ។ ព្រៃមានតែផ្លូវដើរ ។

ធានី ៖ ហើយម្ដាយមីងមករកមីងដល់នេះ ម៉េចបានគាត់ដឹងដំណឹងមីងនៅនេះ?

រី ៖ យើងផ្ដាំសួរសុខទុក្ខអ្នកស្រុកអី ។

ធានី ៖ មានអ្នកស្រុកទៅ?

រី ៖ គេអ្នកផ្សេងចេញចូលដូចក្នុងភូមិស្រុកយើងមានអ្នកដំណើរមកជុំគេមករកកូនចៅផ្ដាំ ។

ធានី ៖ ផ្ដាំគេឲ្យទៅប្រាប់ម្ដាយមីង?

រី ៖ ហ្នឹងហើយ ថាប្រាប់ម៉ែខ្ញុំផងថាខ្ញុំនៅរស់ទេ មិនបាច់គិតគូរកខ្ញុំទេ ប្រាប់អីចឹង ហើយគាត់មិនសុខចិត្ត គាត់ឮថាកូននៅរស់ ចុះបែកតាំងពី៧៩មក ។

ធានី ៖ មីងប្រាប់គេថាមីងនៅកន្លែងៗណាហើយ?

រី ៖ ហ្នឹងហើយប្រាប់ដំណើរទំនង ។

ធានី ៖ ប្រាប់អ្នកណាគេ?

រី ៖ អ្នកមក ។

ធានី ៖ អ្នកមកឈ្មោះអីគេ?

រី ៖ ហ៊ើ! អត់ស្គាល់ អត់ចាំទេយូរហើយ ។

ធានី ៖ ហើយគាត់ស្គាល់ម្ដាយមីង?

រី ៖ បេះពុតៗគ្នា ប្រាប់ថាខ្ញុំឈ្មោះដើមម៉េច ឈ្មោះឥឡូវអីចឹងផ្ដាំ ។

ធានី ៖ ឈ្មោះដើមម៉េច ឈ្មោះឥឡូវម៉េច?

រី ៖ ដូចថាពាក្យខ្នួន ហៅមីងយ៉ុន ហៅខ្នួន ហៅមីនាងអីនៅស្រុកយើងថាកូនយាយប៉ុង ផ្ដាំសួរសុខទុក្ខម៉ែខ្ញុំផង ខ្ញុំនៅរស់មិនបាច់គិតអីទេ ។ ហើយគាត់ឮដំណឹងថា នៅរស់គាត់មកវិញមកទាំងគេទាំងយើងទោះអត់អីមានអីក៏ ឲ្យបានជួបកូន គាត់ដើរ ។

ធានី ៖ គាត់ដើរមក?

រី ៖ ជំនាន់នោះជិះឡានមកចុះនៅត្រង់ណា នៅទឹកថ្លា ។

ធានី ៖ ទឹកថ្លាណា?

រី ៖ ទឹកថ្លាយើងនៅហួសស្វាយ(ស្វាយស៊ីសាផុន) នេះ ។

ធានី ៖ ពីនឹងគាត់ដើរមកដល់នេះ?

រី ៖ ចា៎! ជួនកាលគាត់ចុះពីណាភ្នំតូច ភ្នំធំ ដើរមក បេះដើរជំនាន់នឹង យើងដើរជំនាន់នឹងមិនមានឡានជិះដូចឥឡូវណា ។

ធានី ៖ កាលពេលមកៗតាមផ្លូវនោះ មិនមែនមកពីបាត់ដំបងមកទេ?

រី ៖ មកពីបាត់ដំបង ប៉ុនយើងដើរពីព្រៃលិចយើង។

ធានី ៖ យាយគាត់ដើរម្នាក់ឯង?

រី ៖ មានគេមក ថាទៅរកកូនទាំងគេទាំងឯង ចេះស្វែងរកកូន។

ធានី ៖ មានច្រើនដែល មកជាមួយគាត់ប្រហែលប៉ុន្មាននាក់?

រី ៖ អត់ដឹងដែរ ប៉ុនមកជុំគាត់២នាក់ ដែលអ្នកភូមិខ្ញុំនឹង។ ហើយមកជាមួយអ្នកភូមិផ្សេងៗទៀត។

ធានី ៖ ហើយមីងពេលជួបគាត់ដំបូង មានអារម្មណ៍ម៉េច?

រី ៖ មានអារម្មណ៍រំភើបអរ ហើយយើងបែកម្ដាយយូរ។

ធានី ៖ មើលទៅរូបរាងគាត់ម្ដាយដូចមុនទេ?

រី ៖ អត់ទេ គាត់កាលពីដើមគាត់ក្មេង ឥឡូវគាត់ចាស់ កាលខ្ញុំបែកគាត់អាយុ៤០ជាងឥឡូវ។

ធានី ៖ កាលបែកគាត់បែកនៅណា?

រី ៖ បែកយើងកាលជំនាន់យើងចូលជួរដំបូង ខ្ញុំអធិប្បាយពីដើមដំបូងយើងចូលជួរនៅឃុំនៅតំបន់។

ធានី ៖ មីងបែកតាំងពីពេលនឹងរហូតមកអត់ដែលបានមកលេងផ្ទះ?

រី ៖ ចា៎! បានទៅ៧៥ បានទៅដេក២យប់។ ឆ្នាំរំដោះ៧៥ រំដោះហើយបានទៅដេកផ្ទះ២-៣យប់

ធានី ៖ ហើយក៏ត្រឡប់មកវិញ?

រី ៖ បែកហ្នឹងតាំងពីនឹងរហូត។

ធានី ៖ មីងនៅក្នុងសម័យខ្មែរក្រហម មីងធ្លាប់ជួយអ្នកណាគេ?

រី ៖ ជួយៗតែក្នុងអង្គភាពគ្នាឯងហ្នឹងឯង។

ធានី ៖ ជួយម៉េច?

រី ៖ ជួយឈឺថ្នាត់យប់ព្រលប់ អង្គភាពជួយអ្នកណាផ្សេង បើនៅក្នុងអង្គភាពនឹងគ្រប់គ្រងឈឺយប់ព្រលប់ជួយមើលថែគ្នាទៅវិញទៅមក។

ធានី ៖ អ្នកណាគេឈឺ?

រី ៖ នៅអង្គភាពនឹងប៉ុន្មាននាក់យើងមើលគ្នា។

ធានី ៖ មើលយ៉ាងម៉េច?

រី ៖ មើលត្រង់ថាឈឺយប់ព្រលប់ គេក្ដៅគេគ្រុនរងាយើងជួយមើលគ្នា។

ធានី ៖ មីងលើកឧទាហរណ៍ឈ្មោះ២-៣នាក់?

រី ៖ វាបែកគ្នា ភ្លេចហើយ។ ហ្នឹងហើយយើងជួយមើលថែគ្នាទៅវិញទៅមក អ្នកណាត្រូវយកទៅពេទ្យ។

ធានី ៖ អត់ចាំឈ្មោះ?

រី ៖ អត់ចាំ វាយូរពេកហើយ ។

ធានី ៖ ចុះដែលមានអ្នកណាធ្វើខុសអី ហើយមីងប្រាប់ថា?

រី ៖ ហ្នឹងហើយជួយៗជាមតិ យើងជួយជំនាន់នឹង ។

ធានី ៖ ជួយមតិជាម៉េច?

រី ៖ ជួយមតិដូចថាយើងកុំធ្វើអីចឹង វាមិនត្រឹមត្រូវវាខុសវាឆ្គងដល់អត្តភាពយើង ។

ធានី ៖ តែដឹងថាមានអ្នកណាគេធ្វើខុសធ្ងន់ មានអ្នកផ្សេងគេដាក់ទោសគាត់ មីងទៅជួយ?

រី ៖ ទេ!អត់ដឹងអានឹងអត្តភាពខ្ញុំអត់ដែលមានអ្នកណាខុសឆ្គងអត់ដែលមានអ្នកណាវែតប់អីជង គ្រាន់ខុសឆ្គងយើងតិចតួចការងាររអាចតំរែតំរង់គ្នាបាន ។

ធានី ៖ ចិត្តរបស់មីងផ្ទាល់ តើមីងយល់ថាការផ្សះផ្សា ការត្រូវរូវគ្នា ត្រូវរូវគ្នា គួរតែធ្វើនៅជិត ឬនៅឆ្ងាយល្អជាង របៀបថាយើងនៅជិតគ្នាល្អជាង ឬយើងអ្នកនៅឆ្ងាយ?

រី ៖ ជិតល្អជាង ។

ធានី ៖ ជិតល្អជាង?

រី ៖ ចា៎!ហ្នឹងហើយ ជិតល្អជាង បើយើងនៅឆ្ងាយក៏យើងក្តាប់គ្នាមិនបាន ឧទាហរណ៍ផ្ទះអីចឹងៗខុសត្រូវអីយើងណែនាំទៅ ឧទាហរណ៍ដូចបច្ចុប្បន្នយើងមានក្រុមមានពួក យើងនៅតាមក្រុម ។ អ្នកឯងកុំឈ្លោះប្តីប្រពន្ធអ្នកឯងវាមិនត្រឹមត្រូវទេ វាមិនល្អទេ បើយើងរកស៊ីក៏វាមិនរីកចំរើនដែរ រវល់តែឈ្លោះគ្នា ។ យើងណែនាំគ្នាអីចឹង ឲ្យវាត្រង់កុំឲ្យវាវាច ។

ធានី ៖ មីងមាននៅសល់រូបថតចាស់ៗ?

រី ៖ រូបថតអី?

ធានី ៖ រូបថត៨០ជាង?

រី ៖ អត់មានដែលស្គាល់រូបថតទេ ។

ធានី ៖ ចុះកាលសម័យខ្មែរក្រហមអីអត់មានថតរូបថតអី?

រី ៖ អត់មានទេ អត់ដែលស្គាល់រូបថត ហ្វីលថតម៉េច ។

ធានី ៖ ចុះមានសល់ឯកសារចាស់ដូចជាកាត ឬជាស្អីមួយ?

រី ៖ អត់ៗដែលមាន រលីងស្អាតល្អ ។

ធានី ៖ ទទេរស្អាត?

រី ៖ ចា៎! អត់មាន ។

ធានី ៖ មីងកាលនឹងធ្លាប់បានចូលរៀន?

រី ៖ ខ្ញុំរៀនតាំងពីសម័យយើងនៅស្ទើរ យូរហើយរៀនកើតជា ។

ធានី ៖ មើលអក្សរដាច់ទេ?

រី ៖ បានទើបមើលរួច សរសេរកើតតិចៗ ប៉ុនមិនលះដូចយើងក្មេងឥឡូវវាចេះស្ទាត់ជំនាញ បាន មើល សរសេរកើតឈ្មោះខ្លួនឯង ហើយកូនអ្នកស្រែចចំការវាមិនបានរៀនជិតដល់ដូចយើង គេឥឡូវ ហើយខ្ញុំកូនអ្នកស្រុកភ្នំដែរ ជំនាន់ដើមនៅគៀនឆ្ងាយពីផ្សារ ។

ធានី ៖ ក្បែរភ្នំអីគេ?

រី ៖ ខាងលិចភ្នំស្រង់ ។

ធានី ៖ ខាងលិចភ្នំស្រង់ ខេត្តកំពង់ស្ពឺ?

រី ៖ ចា៎! នៅឆ្ងាយពីផ្សារ សាលារៀនមានដែរ តែយើងជីវភាពឪពុកម្ដាយមិនសូវមានដូចគេ ម៉ា ល្មមគ្រប់គ្រាន់ហូប តែក៏មិនមានដូចថាធូរធារ ។

ធានី ៖ មីងមានអីចង់សួរខ្ញុំវិញ?

រី ៖ អត់មានអីទេ ។

ធានី ៖ ពេលខ្ញុំសួរអីមានការភ័យខ្លាច ឬក៏ឆ្ងល់អី?

រី ៖ អត់ភ័យខ្លាច អត់ឆ្ងល់អីទេ ប៉ុនគ្រាន់ថាវាមិនដែលគេសម្ភាសន៍ខ្ញុំផ្ទាល់ រស់នៅថាសម្ភាសន៍រឿង អី ។

ធានី ៖ អត់ហ៊ាននិយាយ?

រី ៖ ចា៎!

ធានី ៖ អៀន?

រី ៖ អត់អៀនអីទេ យើងមិនសូវប្រសព្វនិយាយក្បោះក្បាយ យើងមិនដែលទំនាក់ទំនងគេអ្នកមក សម្ភាសន៍ និយាយត្រង់ៗមិនចេះនិយាយសមគួរគោរពអី ។

ធានី ៖ ចា៎! អត់អីទេមីង ។ អីចឹង អរគុណច្រើនមីង មីងបានជួយផ្ដល់បទសម្ភាសន៍ ។

រី ៖ ចា៎! ខុសត្រូវអីកែសម្រួល ខ្ញុំមិនសូវប្រសព្វនិយាយទេ ។

«ចប់»